# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៨៣ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការរៀបចំ និងការប្រព្រឹត្តទៅរបស់ អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៤/២៨៤ ចុះថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៦៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៨ ស្តីពីការកែសម្រួល

មាត្រា៤ នៃអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី

- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី០៦ ខែកុម្ភៈ ឆ្នាំ២០០៩ ស្តីពីការកែសម្រួលមាត្រា៤ថ្មី នៃអនុក្រឹត្យលេខ ៦៨ នអនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៤ ស្តីពីការកែប្រែមាត្រា៤ នៃអនុក្រឹត្យលេខ ៨៨ នអនក្រ.បក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការបង្កើតក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី៣០ខែកក្កដាឆ្នាំ២០១០

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដែលសរសេរកាត់ថា **អ.ក.គ.ដ.**។

## ជំពូកទី២

## បេសកកម្ម តួនាទីនិងភារកិច្ចរបស់ អ.ក.គ.ដ.

**មាត្រា២.-**

**អ.ក.គ.ដ.** មានបេសកកម្មផ្តួចផ្តើមលើកសំណើ និងរៀបចំគោលនយោបាយក្នុងវិស័យដីធ្លីស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល និងទៅតាមការណែនាំ និងការចង្អុលទិសរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា៣.-**

**អ.ក.គ.ដ.** មានតួនាទីជាសេនាធិការ និងជាអង្គភាពប្រតិបត្តិ នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លីមានភារកិច្ចដូចតទៅ ៖

១-ផ្តួចផ្តើមគំនិតសិក្សា រៀបចំ និងអភិវឌ្ឍគោលនយោបាយដីធ្លីទូលំទូលាយ ហៅកាត់ " សៀវភៅសដីធ្លី " ដើម្បីតម្រង់ទិសលើការងាររដ្ឋបាលដីធ្លី ការងាររៀបចំដែនដី និងការងារបែងចែកដីធ្លី ឲ្យមានតម្លាភាព និងមានប្រសិទ្ធភាព។

២-ធ្វើការតាមដាន និងវាយតម្លៃលើការអនុវត្តគោលនយោបាយដីធ្លី។

៣-សម្របសម្រួល និងលើកសំណើជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី អំពីការរៀបចំគោលនយោបាយ និងក្របខណ្ឌគតិយុត្តនានាសម្រាប់[illegible]

អនុវត្តកម្មវិធី និងគោលនយោបាយដីធ្លីឲ្យមានប្រសិទ្ធភាព។

៤-លើកសំណើជូនប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យនិងសម្រេចលើ ៖

-ការតែងតាំង ការដំឡើងឋានៈ ឋានន្តរសក្តិ ការផ្ទេរភារកិច្ច ឬការដកមុខតំណែង មន្ត្រីបុគ្គលិក របស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ការជួលទីប្រឹក្សាជាតិ និង/ឬអន្តរជាតិ តាមតម្រូវការចាំបាច់

-ការជ្រើសរើសមន្ត្រីជាប់កិច្ចសន្យា ក្រុមជំនួយការបច្ចេកទេស និងលេខាធិការមួយចំនួន ជាជំនួយការក្នុងការងារប្រចាំថ្ងៃ និង

-ផែនការ សកម្មភាព ការងារ ផែនការថវិកាប្រចាំឆ្នាំ មានជាអាទ៍ ការងារបណ្តុះបណ្តាល និងផ្សព្វផ្សាយ អំពីគោលនយោបាយ និងក្របខណ្ឌគតិយុត្ត ដែលរាជរដ្ឋាភិបាល និងក្រុមប្រឹក្សាគោលនយោបាយ ដីធ្លីបានដាក់ចេញ។

៥-គ្រប់គ្រងរាល់ធនធានរបស់អគ្គលេខាធិការដ្ឋាន រួមមាន ធនធានហិរញ្ញវត្ថុ ធនធានមនុស្ស សម្ភារៈ ព្រមទាំងមធ្យោបាយបំពេញការងារ។

៦-ជួយការងារដល់ក្រុមការងារដែលបានបង្កើតដោយក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

៧-ធ្វើរបាយការណ៍បូកសរុបវាយតម្លៃ ពីលទ្ធផលនៃការអនុវត្តកម្មវិធីគោលនយោបាយកំណែទម្រង់ដីធ្លីជាទៀងទាត់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ និងរាជរដ្ឋាភិបាល តាមរយៈប្រធានក្រុមប្រឹក្សា គោលនយោបាយដីធ្លី។

៨-ធ្វើកំណត់ហេតុនៃកិច្ចប្រជុំ របស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងកិច្ចប្រជុំរបស់ក្រុមការងារ ដែលក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានបង្កើតឡើង។

៩-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀតដែលក្រុមប្រឹក្សាគោលនយោបាយដីធ្លីប្រគល់ជូន។

## ជំពូកទី៣
## រចនាសម្ព័ន្ធ និងការគ្រប់គ្រង

**មាត្រា៤.-**

**អ.ក.គ.ដ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប ដែលជាសមាជិកអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់។

អគ្គលេខាធិការនៃ **អ.ក.គ.ដ.** ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ។

**មាត្រា៥.-**

**អ.ក.គ.ដ.** មានរចនាសម្ព័ន្ធដូចតទៅ ៖

១- ផ្នែកគោលនយោបាយ

២- ផ្នែកបទដ្ឋានគតិយុត្ត

៣-ផ្នែករដ្ឋបាល ពង្រឹងស្ថាប័ន និងហិរញ្ញវត្ថុ

អង្គការលេខរបស់ **អ.ភ.គ.ដ.** ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៦.-**

ផ្នែកនីមួយៗដឹកនាំដោយប្រធានផ្នែក ១ (មួយ) រូប អមដោយអនុប្រធានផ្នែកមួយចំនួនតាមការចាំបាច់។

ប្រធានផ្នែកនីមួយៗមានឋានៈស្មើនឹងប្រធាននាយកដ្ឋាន។

អនុប្រធានផ្នែកនីមួយៗមានឋានៈស្មើនឹងអនុប្រធាននាយកដ្ឋាន។

ផ្នែកនីមួយៗមានការិយាល័យមួយចំនួនតាមការចាំបាច់។

ការរៀបចំ និងការប្រព្រឹត្តទៅរបស់ការិយាល័យចំណុះផ្នែកនីមួយៗ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដែលជាប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា៧.-**

**អ.ភ.គ.ដ.** មានមន្ត្រីបម្រើការងារមកពីក្របខណ្ឌមុខងារសាធារណៈ។ ក្នុងករណីចាំបាច់ **អ.ភ.គ.ដ.** អាចស្នើសុំជ្រើសរើសមន្ត្រីជាប់កិច្ចសន្យាឲ្យមកបម្រើការងារបាន។

**មាត្រា៨.-**

**អ.ភ.គ.ដ.** មានសិទ្ធិប្រើប្រាស់ត្រារបស់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៤
## ភារកិច្ចរបស់ផ្នែកនីមួយៗ

**មាត្រា៩.-**

ផ្នែកគោលនយោបាយ មានភារកិច្ច ដូចតទៅ ៖

-រៀបចំ តាមដាន ត្រួតពិនិត្យការអនុវត្តគោលនយោបាយដីធ្លីទូលំទូលាយ ហៅថា " សៀវភៅសដីធ្លី "

-ធ្វើការវិភាគគោលនយោបាយ និងទំនាក់ទំនងពិគ្រោះយោបល់ដើម្បីរកការឯកភាព និងការគាំទ្រពីគ្រប់ក្រសួងស្ថាប័ន និងអ្នកពាក់ព័ន្ធក្នុងវិស័យដីធ្លី ពិសេសពីប្រជាពលរដ្ឋដែលមានផលប្រយោជន៍លើគោលនយោបាយដីធ្លី

-លើកសំណើគោលនយោបាយកំណែទម្រង់ដីធ្លី ទស្សនាទាន ផែនការកម្ម ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លី ដើម្បីពិនិត្យ និងសម្រេច

-ផ្តួចផ្តើម និងលើកសំណើផែនការយុទ្ធសាស្ត្រនៃការអនុវត្តគោលនយោបាយដីធ្លីរបស់រាជរដ្ឋាភិបាលដាក់ជូនក្រុមប្រឹក្សាគោលនយោបាយដីធ្លីពិនិត្យ និងសម្រេច

-ធ្វើរបាយការណ៍ពីសកម្មភាព និងលទ្ធផលការងារដែលផ្នែកសម្រេចបានផ្តល់ជូនផ្នែករដ្ឋបាល ពង្រឹង ស្ថាប័ន និងហិរញ្ញវត្ថុ ដើម្បីបូកសរុបជូនប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា១០.-**

ផ្នែកបទដ្ឋានគតិយុត្ត មានភារកិច្ច ដូចតទៅ ៖

-ជំរុញការកសាងច្បាប់ បទប្បញ្ញត្តិ បទបញ្ជា សម្រាប់ដំណើរការការងារគ្រប់គ្រងប្រើប្រាស់ និងបែងចែកដីធ្លី ប្រកបដោយប្រសិទ្ធភាព

-លើកវិធានការជាយុទ្ធសាស្ត្រ ដើម្បីទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លី

-តាមដាន វាយតម្លៃ និងលើកសំណើយុទ្ធសាស្ត្រក្នុងការអនុវត្ត និងអភិវឌ្ឍនីតិវិធីដើម្បីជំរុញ និងធានា និរន្តរភាព ប្រសិទ្ធភាព តម្លាភាព និងសមធម៌នូវការងារចុះបញ្ជីដីធ្លី ការងាររៀបចំ ដែនដី នគរូបនីយកម្ម និងការងារបែងចែកដីធ្លី

-ធ្វើរបាយការណ៍ពីសកម្មភាព និងលទ្ធផលការងារដែលផ្នែកសម្រេចបាន

-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី។

**មាត្រា១១.-**

ផ្នែករដ្ឋបាល ពង្រឹងស្ថាប័ន និងហិរញ្ញវត្ថុ មានភារកិច្ច ដូចតទៅ ៖

ក. ការងាររដ្ឋបាល ៖

-គ្រប់គ្រងការងាររដ្ឋបាលរបស់អគ្គលេខាធិការដ្ឋាន

-ធ្វើរបាយការណ៍បូកសរុបពីសកម្មភាព និងលទ្ធផលនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ដីធ្លី របស់រាជរដ្ឋាភិបាលដាក់ជូនសម័យប្រជុំក្រុមប្រឹក្សាគោលនយោបាយដីធ្លីពិនិត្យ និងដើម្បីមានទិសណែនាំអនុវត្តបន្ត

-រៀបចំ និងសម្រួល ធ្វើលេខាធិការកត់ត្រាកិច្ចប្រជុំ ឬសិក្ខាសាលា និងការពិភាក្សារបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី រួមទាំងក្រុមការងារដែលក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានបង្កើតឡើង

-ធ្វើរបាយការណ៍ការងារ និងសកម្មភាពផ្សេងៗរបស់អគ្គលេខាធិការដ្ឋាន

-រក្សាទុកឯកសាររបស់ក្រុមប្រឹក្សាគោលនយោបាយដីធ្លី និង **អ.ក.គ.ដ.**

-សម្របសម្រួលជាមួយក្រសួងស្ថាប័នជំនាញ ដើម្បីទទួលបានព័ត៌មាន និងកម្មវិធីនានាសម្រាប់សិក្សាស្វែងយល់របស់ក្រុមការងារដែលក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានបង្កើតឡើង និងរបស់ទីប្រឹក្សា ឬអ្នកជំនាញការជាតិ អន្តរជាតិដែលនៅអម **អ.ក.គ.ដ.**។

ខ. ការងារពង្រឹងស្ថាប័ន ៖

-ធ្វើទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍ និងអ្នកពាក់ព័ន្ធដើម្បីជំរុញឲ្យមានទំនើបកម្មឧបករណ៍ និងធនធានមនុស្សប្រកបដោយឯកទេសគ្រប់គ្រាន់ ដើម្បីបំពេញការងារក្នុង **អ.ក.គ.ដ.**

-លើកផែនការបណ្តុះបណ្តាល និងផ្សព្វផ្សាយដល់ស្ថាប័នពាក់ព័ន្ធ និងប្រជាពលរដ្ឋទូទៅទាក់ទងទៅនឹងការបញ្ជ្រាបទស្សនៈយល់ដឹងឲ្យបានទូលំទូលាយអំពីគោលនយោបាយ និងក្របខណ្ឌគតិយុត្តនានាទាក់ទងនឹងដីធ្លី ដែលរាជរដ្ឋាភិបាល ក៏ដូចជាក្រុមប្រឹក្សាគោលនយោបាយដីធ្លីបានដាក់ចេញ។

គ. ការងារហិរញ្ញវត្ថុ ៖

-កសាងគម្រោងថវិកាប្រចាំឆ្នាំ និងគ្រប់គ្រងការអនុវត្តថវិកានៃ **អ.ក.គ.ដ.**

-គ្រប់គ្រងចលនទ្រព្យ អចលនទ្រព្យ សន្និធិសម្ភារៈ និងធ្វើបញ្ជីសារពើភណ្ឌនៃ **អ.ក.គ.ដ.**

-រៀបចំផែនការចំណាយនានាសម្រាប់ផ្នែកផ្សេងៗនៃ **អ.ក.គ.ដ.**

-លើកសំណើចំណាយលើសម្ភារៈសម្រាប់គាំទ្រដល់ដំណើរការនៃ **អ.ក.គ.ដ.**

-ធ្វើរបាយការណ៍ចំណាយប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆ្នាំ សម្រាប់ **អ.ក.គ.ដ.**

-រក្សាឲ្យបានត្រឹមត្រូវនូវរាល់ឯកសារសម្រាប់ធ្វើសវនកម្ម

-សហការជាមួយនាយកដ្ឋានផែនការ សេដ្ឋកិច្ច និងហិរញ្ញវត្ថុ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ដើម្បីសម្រួលដល់ការងាររៀបចំ និងការចំណាយថវិកា។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា១២.-**

បទប្បញ្ញត្តិនៃអនុក្រឹត្យលេខ៩៦អនក្រ.បក ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី និងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ប្រធានក្រុមប្រឹក្សាគោលនយោបាយដីធ្លី រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ [illegible] ឆ្នាំ២០១០

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៨៣ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ៦ ឆ្នាំ២០១០**

**រចនាសម្ព័ន្ធរបស់អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាគោលនយោបាយដីធ្លី**

